**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# គណៈវិជ្ជាជីវៈសុខាភិបាលកម្ពុជា

**ជម្រាបជូន**

**លោក គួច ម៉េងលី**

**កម្មវត្ថុ:** ការសុំឲ្យកែតម្រូវអត្ថបទដែលបានចុះផ្សាយលើទំព័រកាសែតភ្នំពេញប៉ុស្តិ៍ និងនៅលើគេហទំព័ររបស់ភ្នំពេញប៉ុស្តិ៍ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៦។

**យោង :** - កាសែតភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៦ លេខ-1605.

- គេហទំព័ររបស់ភ្នំពេញប៉ុស្តិ៍ www.postkhmer.com/នរណាជានរណា/ពីក្មេងល្ងង់ខ្លៅក្រីក្រ-ដើររើសចំណីតាមផ្លូវបរិភោគ-ទៅជាសេដ្ឋីចិត្តធម៌ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៦។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ គណៈវិជ្ជាជីវៈសុខាភិបាលកម្ពុជា សូមជម្រាបលោកថា នៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៦ កាសែតភ្នំពេញប៉ុស្តិ៍បានសម្ភាសជាមួយនឹងលោកផ្ទាល់ និងបានចុះផ្សព្វផ្សាយអត្ថបទសារព័ត៌មានជាសាធារណៈក្រោមចំណងជើង " ពីក្មេងល្ងង់ខ្លៅក្រីក្រដើររើសចំណីតាមផ្លូវបរិភោគទៅជាសេដ្ឋីចិត្តធម៌ "។ ទាក់ទងទៅនឹងអត្ថបទសារពត៌មាននៃទំព័រកាសែតភ្នំពេញប៉ុស្តិ៍ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៦, លោកបាននិយាយថា " ខ្ញុំអត់ដែលជួបពេទ្យណាអាក្រក់សែនអាក្រក់ដូចពេទ្យនៅស្រុកខ្មែរយើងទេ។ គាត់គ្មានវិជ្ជាជីវៈគ្មានភាពទន់ភ្លន់ គ្មានមេត្តាធម៌ នេះខ្ញុំមិនមែននិយាយទាំងអស់ទេខ្ញុំនិយាយបើខ្ញុំបានជួប ១០មាន អាក្រក់៩។ បើមានអាកប្បកិរិយាមារយាទអន់ខ្លួត អៀឈ្លើយ ម៉ាបាវ តើកូនខ្មែរយើងអភិវឌ្ឍយ៉ាងម៉េចទៅ។ ពេលគេទៅព្យាបាលម្ដងសឹងតែលុតជង្គង់អង្វរគាត់ (ពេទ្យ)។ ពេទ្យដែលគ្មានជំនាញវិជ្ជាជីវៈ ក្រមសីលធម៌ទាំងនោះហើយជាអ្នកសម្លាប់មនុស្ស។ "។

ក្រោយពីបានពិនិត្យមើលអត្ថបទសារពត៌មាននៅលើទំព័រកាសែតភ្នំពេញប៉ុស្តិ៍រួចមក គណៈវិជ្ជាជីវៈសុខាភិបាលកម្ពុជាចាត់ទុកថា ការលើកឡើងរបស់លោកជាការវាយតម្លៃដែលគ្មានមូលដ្ឋាន គ្មានវិជ្ជាជីវៈ

គ្មានការទទួលខុសត្រូវ និងមានចរិតបំភ្លើស បន្ថុះបង្អាប់ ដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កិត្តិយស សេចក្តីថ្លៃថ្នូររបស់គ្រូពេទ្យ និងអ្នកវិជ្ជាជីវៈសុខាភិបាលកម្ពុជា ។

ចំពោះការនិយាយបរិហារកេរ្តិ៍ និងប្រមាថជាសាធារណៈរបស់លោកមកលើគ្រូពេទ្យ និងអ្នកវិជ្ជាជីវៈសុខាភិបាល គណៈវិជ្ជាជីវៈសុខាភិបាល សុំឲ្យលោកធ្វើការកែតម្រូវ និងសុំទោសជាសាធារណៈ ចំពោះពាក្យសម្តីរបស់លោក។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកធ្វើការកែតម្រូវ និងសុំទោសជាសាធារណៈ ជាចាំបាច់។

ធ្វើនៅភ្នំពេញ, ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦

**គណៈគ្រូពេទ្យកម្ពុជា**
**ប្រធាន**

សាស្ត្រាចារ្យវេជ្ជ. ងា ហ្វួយ

**គណៈទន្តពេទ្យកម្ពុជា**
**ប្រធាន**

[illegible] សុខុម_រិទ្ធីឌុង

**គណៈគិលានុបដ្ឋាកកម្ពុជា**
**ប្រធានស្តីទី**

អ៊ុន សាន

**គណៈឆ្មបកម្ពុជា**
**ប្រធាន**

អ៊ុង_ពិជា